ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខៈ ០៨៧/២៥ គ.ជ.ប.ជ

# របាយការណ៍
# ស្តីពី
# ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ប្រចាំខែមេសា និងទិសដៅខែឧសភា ឆ្នាំ២០២៥

## I. ស្ថានភាពទូទៅ

ពិភពលោក កំពុងតែប្រឈមដោះស្រាយវិបត្តិសេដ្ឋកិច្ចជាសាកល ផលប៉ះពាល់នៃគ្រោះធម្មជាតិ ដែលកើតឡើងដោយបម្រែបម្រួលអាកាសធាតុ និងសង្គ្រាមប្រដាប់អាវុធដ៏រ៉ាំរ៉ៃ ដែលជំរុញឱ្យមនុស្សរាប់រយលាននាក់បង្ខំចិត្តចាកចេញពីផ្ទះសម្បែង ឬទីតាំងដែលខ្លួនរស់នៅ ហើយធ្វើទេសន្តរប្រវេសន៍ដោយគ្មានការត្រៀមទុក ដែលក្លាយជាចលនាលំហូរពលករដែលគ្មានឯកសារ ខ្វះការគ្រប់គ្រង ដែលប្រឈមយ៉ាងខ្លាំងទៅនឹងកង្វះសុវត្ថិភាព អំពើរំលោភបំពាន និងការកេងប្រវ័ញ្ចជាច្រើនរូបភាព។

ការផ្សព្វផ្សាយយ៉ាងទូលំទូលាយរបស់បណ្តាញសារព័ត៌មាននានា ទាំងពិត ទាំងមិនពិត អំពីបទល្មើសជួញដូរមនុស្សនៅកម្ពុជា ព្រមទាំងការចាទប្រកាន់ពីបណ្តាប្រទេស ដែលមានពលរដ្ឋមកប្រព្រឹត្តបទល្មើស ឬមករងគ្រោះនៅកម្ពុជា បានធ្វើឱ្យមានការភ័ន្តច្រឡំ និងវាយតម្លៃជាអវិជ្ជមានលើស្ថានភាពសន្តិសុខនៅកម្ពុជា ដែលនាំឱ្យមានភាពរាំងស្ទះដល់ដំណើរការនៃចរន្តសេដ្ឋកិច្ចជាតិ និងប៉ះពាល់ដល់ជីវភាពរបស់ប្រជាពលរដ្ឋ។

ការផ្សព្វផ្សាយអំពីឱកាសការងារ និងការជ្រើសរើសពលករទៅធ្វើការនៅក្រៅប្រទេស ទាំងតាមប្រព័ន្ធផ្លូវការ ទាំងតាមបណ្តាញសង្គម និងមួយចំនួនធំជាការអូសទាញរបស់បណ្តាញជនល្មើស បានក្លាយជាកត្តាជំរុញ និងទាក់ទាញប្រជាពលរដ្ឋក្នុងតំបន់ និងពីបណ្តាប្រទេសនានាក្នុងពិភពលោក ក៏ដូចជាប្រជាជនកម្ពុជា ដែលពេញវ័យការងារឱ្យចាប់អារម្មណ៍ និងសម្រេចចិត្តយ៉ាងឆាប់រហ័ស និងផុលផុស ក្នុងការធ្វើចំណាកស្រុក ឬធ្វើទេសន្តរប្រវេសន៍ទៅរកការងារ ដែលមានបៀវត្សរ៍ខ្ពស់ ជាពិសេសពាក់ព័ន្ធនឹងសកម្មភាពឆបោក។ ចំនួនដ៏ច្រើនលើសលប់នៃប្រជាជនពេញវ័យការងារបានធ្វើចំណាកស្រុក មានរហូតដល់ជាងមួយលាននាក់ បាននិងកំពុងនៅធ្វើការងាររហូតដល់ប្រមាណ ១.៦លាននាក់ នៅក្រៅប្រទេស ដែលស្មើនឹងជិត២០ភាគរយ នៃប្រជាពលរដ្ឋវ័យ ពី១៥ឆ្នាំ ទៅ ៦០ឆ្នាំ និងអត្រាដ៏ខ្ពស់នៃការបោះបង់ការសិក្សាក្នុងកម្រិតមធ្យមសិក្សា បានប៉ះពាល់ទៅនឹងកង្វះធនធានពលកម្ម សម្រាប់ទទួលយកការងារដែលត្រូវបានបង្កើតឡើងក្នុងស្រុក តាមរយៈការវិនិយោគលើវិស័យឧស្សាហកម្ម និងសហគ្រាសធំៗ ដែលរាជរដ្ឋាភិបាលបាននិងកំពុងទាក់ទាញការចាប់អារម្មណ៍ពីអន្តរជាតិ។

រាជរដ្ឋាភិបាលក្នុងនីតិកាលទី៧ បានចាត់ទុកការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាអាទិភាពមួយក្នុងចំណោមអាទិភាពដទៃទៀត រួមទាំងផលប៉ះពាល់នៃគ្រឿងញៀន គ្រឿងស្រវឹង គ្រោះថ្នាក់ចរាចរណ៍ និងបានដាក់ចេញនូវយុទ្ធសាស្ត្រឆ្លើយតបកាន់តែមានប្រសិទ្ធភាព ដោយខិតខំជំរុញសកម្មភាពឥតឈប់ឈរ ដើម្បីការពារសុវត្ថិភាព និងសន្តិសុខមនុស្ស ក៏ដូចជាសន្តិសុខជាតិទាំងមូល ដើម្បីទ្រទ្រង់ដំណើរការអភិវឌ្ឍន៍គ្រប់វិស័យ។

នៅក្នុងខែមេសានេះ គ្រប់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាព និងរាជធានី-ខេត្ត ក្នុងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅគ្រប់កម្រិត ដោយមានការចូលរួមគាំទ្រ និងសហការពីអង្គការដៃគូជាតិ និងអន្តរជាតិពាក់ព័ន្ធ បានធ្វើសកម្មភាពប្រតិបត្តិការយ៉ាងសកម្ម តាមយុទ្ធសាស្ត្រទាំងបួន នៃផែនការយុទ្ធសាស្ត្រជាតិ ដោយប្រឈមនឹងស្ថានភាពប្រែប្រួលឥតឈប់ឈរនៃបទល្មើស។

## II. លទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

### ក. ការងារច្បាប់ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត និងកិច្ចសហប្រតិបត្តិការ (គ្មាន)

### ខ. ការបង្ការ ទប់ស្កាត់

#### ខ.១. ការលើកកម្ពស់ការយល់ដឹងតាមរយៈការអប់រំផ្សព្វផ្សាយដោយផ្ទាល់

ក្រុមការងារបង្ការ ទប់ស្កាត់ នៃ គ.ជ.ប.ជ ដឹកនាំដោយក្រសួងអប់រំ យុវជន និងកីឡា ដែលមានស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សហការជាមួយអង្គការដៃគូ បានធ្វើការផ្សព្វផ្សាយតាមរយៈ ការអនុវត្តគោលនយោបាយ "ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព" វេទិកាសាធារណៈ និងការបញ្ជ្រាបការផ្សព្វផ្សាយតាមកម្មវិធីផ្សេងៗ សរុបចំនួន **១៨.១០៦**លើក មានអ្នកចូលរួមសរុបចំនួន **១.០១១.៨២២**នាក់ ក្នុងនោះស្ត្រី **៥០៨.៩៦៨**នាក់ (ធៀបនឹងខែមីនា មានចំនួន **៩០២.៧៣៣**នាក់) គឺមានការកើនឡើងចំនួន **១០៩.០៨៩**នាក់ ស្មើនឹង**១២,០៨%** ដូចមានក្នុងតារាងខាងក្រោម៖

*តារាងទិន្នន័យសរុបការផ្សព្វផ្សាយដោយផ្ទាល់*

| ល.រ | សកម្មភាពផ្សព្វផ្សាយ | ចំនួនដង/លើក | ចំនួនអ្នកចូលរួម | ចំនួនស្ត្រី |
|---|---|---|---|---|
| ០១ | ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព និងវេទិកាសាធារណៈ | **១៦.៩៨៤លើក** | **៩៤៤.៤៤៥នាក់** | **៤៨០.១៣៥នាក់** |
| ០២ | កម្មវិធីផ្សេងៗ | **១.១២២លើក** | **៦៧.៣៧៧នាក់** | **២៨.៨៣៣នាក់** |
| | សរុប | **១៨.១០៦លើក** | **១.០១១.៨២២នាក់** | **៥០៨.៩៦៨នាក់** |
| *(<u>សម្គាល់</u>៖ ចំនួននេះមិនគិតអ្នកដែលបានទទួលព័ត៌មានតាមរយៈការចែកខិត្តប័ណ្ណ បណ្តាញសង្គម ឬការផ្សព្វផ្សាយតាមប្រព័ន្ធអេឡិកត្រូនិកផ្សេងទៀតឡើយ)* | | | | |

❖ **ការផ្សព្វផ្សាយតាមរយៈវេទិកាសាធារណៈ និងភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព**

| ល.រ | ក្រសួង ស្ថាប័ន | ផ្សព្វផ្សាយ ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព | | | វេទិកាសាធារណៈ | | |
|---|---|---|---|---|---|---|---|
| | រាជធានី-ខេត្ត | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី |
| **រាជធានី-ខេត្ត** | | | | | | | |
| ១ | រាជធានីភ្នំពេញ | ៨៦ | ៩.៦៩៩ | ៤.៧៣២ | ២៤ | ១.៤១៧ | ៧៤៩ |
| ២ | កណ្តាល | | | | ៨៣៥ | ៣៩.៤៧៧ | ២១.៧៣១ |
| ៣ | បាត់ដំបង | ១.០៤៦ | ៥១.៤៦៧ | ២៦.៦៧៩ | ៦៨៦ | ២១.៧២០ | ១១.៩១២ |
| ៤ | ពោធិ៍សាត់ | ៦០៦ | ៦៤.៧២៧ | ៣៣.៦៣២ | ៣.៣៣ | ១៤.០៣៣ | ៦.៦១៩ |
| ៥ | សៀមរាប | ៧២៥ | ៥៧.១២២ | ៣៣.៥៦៨ | ៥៤៥ | ២២.១០១ | ១៣.២៣១ |
| ៦ | កំពង់ឆ្នាំង | ៨០០ | ២៨.០៥០ | ១៥.០៧៧ | ៣៥៣ | ១៣.៧៤៩ | ៧.០០៩ |
| ៧ | កំពង់ចាម | ១.៦៧៨ | ៩៥.៨១២ | ៤៩.៣១៥ | ១ | ១០០ | ៤១ |
| ៨ | ព្រះសីហនុ | ១៤៤ | ៤.៤៩០ | ២.០២៥ | ៤៩ | ១.៦៩៦ | ៨០៩ |
| ៩ | ព្រះវិហារ | ១១ | ១.៣៣២ | ៨៥១ | | | |
| ១០ | ស្វាយរៀង | ៣២៧ | ២២.៧៩០ | ១២.៨២១ | ៥២០ | ១៨.៣៧៨ | ១០.៥៣៤ |
| ១១ | ប៉ៃលិន | ៦ | ៥.៣៨៥ | ២.២៦៥ | ១០៦ | ៣.៨៦២ | ២.០៣២ |
| ១២ | កោះកុង | ១.០៧០ | ១៥.០៩៩ | ១.៧២៧ | ៤៦៤ | ៧.១៨៤ | ២.៩៣២ |
| ១៣ | កំពត | | | | ២៥ | ២.៣៨១ | ១.៣១០ |
| ១៤ | កំពង់ធំ | ៩៣៥ | ២០៩.៩៣២ | ៩៨.០៤៥ | ២៦១ | ៩.៨៦០ | ៥.៥៧០ |
| ១៥ | តាកែវ | | | | | | |
| ១៦ | ក្រចេះ | ៦៨ | ១.៧៦៨ | ៨៣៥ | | | |
| ១៧ | កែប | ៨៥ | ៨.៣៦៥ | ៤.១៧៤ | ១២៧ | ៥.២៤៧ | ២.៧៥៦ |
| ១៨ | កំពង់ស្ពឺ | ៣០៥ | ១៧.៥៣២ | ៩.៦៦៩ | ៧៤ | ៦.៣៨២ | ៣.៣៦៣ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១៩ | ស្ទឹងត្រែង | | | | ២១០ | ៧.៥០៩ | ៤.៣១៧ |
| ២០ | រតនគិរី | ៥៧៨ | ២៣.៧៧៤ | ១២.០១៤ | ២៣៥ | ១១.៧៦០ | ៥.៥៩៤ |
| ២១ | ព្រៃវែង | ១.១៥៩ | ៧៣.០២៩ | ៣៥.១៩០ | ៧៥១ | ២៣.៩០១ | ១៣.៧១៤ |
| ២២ | ត្បូងឃ្មុំ | ៥០ | ៣.៨៨៩ | ១.៩៨៧ | ១២៦ | ៣.៨១៧ | ១.៨០៣ |
| ២៣ | បន្ទាយមានជ័យ | ៩៤៨ | ១៥.២៣៨ | ៨.៦៣២ | ៣៣៣ | ៨.០៤៦ | ៤.៣៨៤ |
| ២៤ | ឧត្តរមានជ័យ | ១៣៤ | ៦.៩៧០ | ៣.៨៩១ | ១៣ | ១.៥៦៨ | ៨៦៦ |
| ២៥ | មណ្ឌលគិរី | ១៤៨ | ៣.៦២៤ | ១.៦៤៧ | ៤ | ១៦៣ | ៨៣ |
| សរុប រាជធានី-ខេត្ត | | ១០.៩០៩លើក | ៧២០.០៩៤នាក់ | ៣៥៨.៧៧៦នាក់ | ៦.០៧៥លើក | ២២៤.៣៥១នាក់ | ១២១.៣៥៩នាក់ |
| សរុបរួម | | ១៦.៩៨៤លើក | | ៩៤៤.៤៤៥នាក់ | | ៤៨០.១៣៥នាក់ | |

❖ **ការបញ្ជ្រាបការយល់ដឹងតាមរយៈកម្មវិធីផ្សេងៗ**

| ល.រ | ក្រសួង ស្ថាប័ន រាជធានី-ខេត្ត | ចំនួនលើក | ចំនួនអ្នកចូលរួម | ចំនួនស្ត្រី |
|---|---|---|---|---|
| ១ | ខេត្តកណ្ដាល | ០៩ | ៦៧១ | ៣១១ |
| ២ | ខេត្តប៉ៃលិន | ០៣ | ១២.២២៥ | ៥៨៤ |
| ៣ | ខេត្តសៀមរាប | ២៦ | ១.៦៩៤ | ១.០០១ |
| ៤ | ខេត្តកំពង់ឆ្នាំង | ៤៩ | ១៣៩៤ | ៧២៩ |
| ៥ | ខេត្តកំពង់ចាម | ០៩ | ៥៦៦ | ១៦០ |
| ៦ | ខេត្តព្រះវិហារ | ០៥ | ៦៦៤ | ២៧០ |
| ៧ | ខេត្តកំពត | ០១ | ២០០ | ១៩២ |
| ៨ | ខេត្តឧត្តរមានជ័យ | ១៦៧ | ៦.៧៧០ | ៣.៧៨៤ |
| ៩ | ខេត្តក្រចេះ | ០១ | ២០ | ១២ |
| ១០ | ខេត្តបន្ទាយមានជ័យ | ១១ | ១.៨៣៣ | ១.១១៣ |
| ១១ | ខេត្តស្ទឹងត្រែង | ៧០៧ | ២.៨២៧ | ១.៥៨៣ |
| ១២ | ខេត្តកំពង់ធំ | ១៣ | ៨២០ | ៤៣៥ |
| ១៣ | ខេត្តតាកែវ | ៧១ | ៣៦.៩២៩ | ១៨.២៥៩ |
| ១៤ | អង្គការ Friend Insertional (សៀមរាប) | ៤៧ | ៦៧៨ | ៣៣៣ |
| ១៥ | អង្គការសាម៉ារីតាន់កឹស(បាត់ដំបង) | ០៣ | ៨៦ | ៦៧ |
| សរុប | | ១.១២២លើក | ៦៧.៣៧៧នាក់ | ២៨.៨៣៣នាក់ |

## ខ.២. ការលើកកម្ពស់ការយល់ដឹងតាមរយៈការអប់រំផ្សព្វផ្សាយដោយមិនផ្ទាល់

❖ **ការផលិត និងចែកផ្សាយសម្ភារផ្ដល់ព័ត៌មាន និងអប់រំ** (IEC = Information Education Communication Materials)

| ល.រ | ក្រសួង ស្ថាប័ន រាជធានី-ខេត្ត | សកម្មភាព និង ឧបករណ៍ផ្សព្វផ្សាយ | ចំនួនលើក | ចំនួនឧបករណ៍ | ចំនួនអ្នកទទួលបាន | ចំនួនស្ត្រី |
|---|---|---|---|---|---|---|
| ១ | សៀមរាប | -ខិត្តប័ណ្ណផ្សព្វផ្សាយ | | ៨.០១៨សន្លឹក | | |
| ២ | ស្ទឹងត្រែង | -ចងបដាផ្សព្វផ្សាយ | | ១៨បដា | ២៦១.៧៧៦ | |
| ៣ | បន្ទាយមានជ័យ | -ខិត្តប័ណ្ណផ្សព្វផ្សាយ | | | ២.០៦៥ | ៤៥០ |
| ៤ | ព្រះវិហារ | -ខិត្តប័ណ្ណផ្សព្វផ្សាយ | ១១ | ១១សន្លឹក | ៤៣៨ | ១១២ |
| ៥ | ឧត្តរមានជ័យ | -ខិត្តប័ណ្ណផ្សព្វផ្សាយ | | ១០៧៥សន្លឹក | | |
| ៦ | អង្គការសាម៉ារីតាន់កឹស (បាត់ដំបង) | -ដំឡើងបាណូផ្សព្វផ្សាយ<br>-ខិត្តប័ណ្ណផ្សព្វផ្សាយ | | ១៩បាណូ<br>៣.១៣១សន្លឹក | | |
| សរុបផ្សព្វផ្សាយ១១លើក មានខិត្តប័ណ្ណ១២.២៣៥សន្លឹក, បដា១៨, បាណូ១៩, អ្នកទទួលបាន២៦៤.២៧៩នាក់ (ស្ត្រី៥៦២នាក់) | | | | | | |

❖ **ការផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ និងប្រព័ន្ធអេឡិកត្រូនិក**

| ល.រ | ក្រសួង ស្ថាប័ន រាជធានី-ខេត្ត | បណ្តាញផ្សព្វផ្សាយ | ចំនួនលើក/ដង/ស្ពត | ចំនួនអ្នកទស្សនា/ស្តាប់/អាន/Views |
|---|---|---|---|---|
| ១ | ខេត្តសៀមរាប | -វិទ្យុជាតិ | ១៩២លើក | |
| ២ | ខេត្តកំពង់ចាម | -វិទ្យុជាតិ | ១៥០លើក | |
| ៣ | ខេត្តព្រៃវែង | -វិទ្យុជាតិ | ៥០លើក | |
| ៤ | ខេត្តត្បូងឃ្មុំ | -វិទ្យុជាតិ<br>-រឿងខ្លី | ១៣០លើក<br>២៣លើក | |
| ៥ | ខេត្តបន្ទាយមានជ័យ | -វិទ្យុជាតិ | ១៦លើក | |
| | | សរុប | ៥៦០លើក | |

❖ **ការចូលរួមជាវាគ្មិនក្នុងកម្មវិធីផ្សេងៗ នៅតាមស្ថានីយវិទ្យុ និងទូរទស្សន៍**

▪ **ខេត្តបាត់ដំបង៖** តំណាងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានចូលរួមជាវាគ្មិនកិត្តិយសក្នុងវេទិកាសាធារណៈ ស្តីពីហិង្សាផ្លូវភេទ អំពើជួញដូរមនុស្ស និងសុវត្ថិភាពពីការធ្វើចំណាកស្រុក អ្នកចូលរួមចំនួន **៦១**នាក់ (ស្រី **២៨**នាក់)។

## ខ.៣. ការបង្ការ ទប់ស្កាត់តាមវិធានការជំនាញ

### ខ.៣.១. ការបង្ការ ទប់ស្កាត់ការជួញដូរមនុស្ស តាមរយៈរូបភាពរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ (ក្រុមការងារអនុវត្តច្បាប់) បានសម្ភាសន៍ជនបរទេស ដែលមកដាក់ពាក្យសុំចុះបញ្ជីរៀបអាពាហ៍ពិពាហ៍ជាមួយពលរដ្ឋខ្មែរ តាមផ្លូវច្បាប់ សរុបចំនួន **១៧៦**នាក់ (ស្រី ០៧នាក់) មាន១៤សញ្ជាតិ។

| បរិយាយ | ចំនួនមនុស្ស | សញ្ជាតិ |
|---|---|---|
| ស្រីបរទេសជាមួយបុរសខ្មែរ | ០៧នាក់ | ចិន១០៣នាក់ កូរ៉េខាងត្បូង ៣៣នាក់(ស្រី០២នាក់) អាម៉េរិក២០នាក់ (ស្រី០៥នាក់) បារាំង០៥នាក់ ម៉ាឡេស៊ី០៣នាក់ អូស្ត្រាលី០២នាក់ ជប៉ុន០២នាក់ កាណាដា ០២នាក់ ស៊ុយអែត០១នាក់ អាល្លឺម៉ង់០១នាក់ អង់គ្លេស០១នាក់ ឥណ្ឌា០១នាក់ ឥណ្ឌូនេស៊ី០១នាក់ និងវៀតណាម០១នាក់។ |
| បុរសបរទេសជាមួយស្រីខ្មែរ | ១៦៩នាក់ | |
| សរុប | ១៧៦ នាក់ | ១៤ សញ្ជាតិ |

❖ **ការផ្សព្វផ្សាយ**

▪ **ខេត្តកំពង់ចាម៖** រដ្ឋបាលក្រុងកំពង់ចាម និងស្រុកស្ទឹងត្រង់ បានផ្សព្វផ្សាយអនុក្រឹត្យ ស្តីពីការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស ដល់ប្រជាពលរដ្ឋ សរុបចំនួន ៨៨លើក អ្នកចូលរួមចំនួន **៤.៧៧៣**នាក់(ស្រី **២.៣៨៧**នាក់)។

### ខ.៣.២. ការគ្រប់គ្រងស្ថិតិចំណាកស្រុក ចំណូលស្រុក ពលរដ្ឋខ្មែរ និងជនបរទេស

❖ ការគ្រប់គ្រងស្ថិតិបច្ចុប្បន្នភាពចំណាកស្រុក ចំណូលស្រុក ពលរដ្ឋខ្មែរ

**អគ្គស្នងការដ្ឋាននគរបាលជាតិ** បានតាមដាន និងធ្វើបច្ចុប្បន្នភាពស្ថិតិពលរដ្ឋខ្មែរចំណាកស្រុកទៅក្រៅប្រទេស និងត្រឡប់មកវិញ តាមរយៈការប្រមូលទិន្នន័យពីបណ្តាស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ទូទាំងប្រទេស ដូចមានក្នុងតារាងខាងក្រោម៖

| ប្រចាំខែ | ទិន្នន័យពលរដ្ឋខ្មែរចំណាកស្រុកទៅក្រៅប្រទេស | | | |
|---|---|---|---|---|
| | សរុប | ស្រី | អនីតិជន | |
| | | | សរុប | ស្រី |
| មេសា | ១៤១.៧២៤នាក់ | ៦៤.១៩៣នាក់ | ៤.៥៦៦នាក់ | ១.៤៣២នាក់ |
| ប្រចាំខែ | **ទិន្នន័យពលរដ្ឋខ្មែរដែលវិលត្រឡប់ពីក្រៅប្រទេស** | | | |
| | សរុប | ស្រី | អនីតិជន | |
| | | | សរុប | ស្រី |
| មេសា | ១៤.៧៤៣នាក់ | ៦.១១៤នាក់ | ២១៧នាក់ | ៨៣នាក់ |

❖ **ការទទួលពលរដ្ឋខ្មែរចំណាកស្រុកដែលអាជ្ញាធរបរទេសបញ្ជូនត្រឡប់**

**<u>ស្ថិតិពលរដ្ឋខ្មែរដែលត្រូវអាជ្ញាធរបរទេសបញ្ជូនត្រឡប់តាមច្រកទ្វារព្រំដែន</u>**

| ល.រ | រាជធានី-ខេត្ត | ចំនួនរួម | ស្រី | អនីតិជន | ស្រី |
|---|---|---|---|---|---|
| ១ | ស្វាយរៀង | ០៤ | ០២ | ០១ | |
| ២ | កោះកុង | ២៧ | ០៣ | | |
| | **សរុប** | **៣១ នាក់** | **០៥ នាក់** | **០១ នាក់** | |

**<u>ការទទួលពលករនៅតាមមណ្ឌលទទួលពលករ</u>**

▪ **មជ្ឈមណ្ឌលសំចត និងស្តារនីតិសម្បទាជនរងគ្រោះប៉ោយប៉ែត** បានទទួលជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងពលករចំណាកស្រុក ដែលបញ្ជូនត្រឡប់ពីប្រទេសថៃ សរុបចំនួន **១.២០៣**នាក់ (ប្រុស **៦៦៤**នាក់ ស្រី **៤២៨**នាក់ កុមារា **៥៤**នាក់ កុមារី **៥៧**នាក់) ក្នុងនោះមានដូចខាងក្រោម៖

- បានទទួលជនរងគ្រោះដោយអំពើជួញដូរមនុស្ស ធ្វើមាតុភូមិនិវត្តន៍ពីប្រទេសថៃចំនួន **០៥**នាក់ (ប្រុស ០១នាក់ ស្រី ០៣នាក់ កុមារី ០១នាក់) ជាករណីកេងប្រវ័ញ្ចកម្លាំងពលកម្ម ០២នាក់ (ប្រុស ០១នាក់ ស្រី ០១នាក់) និងងាយរងគ្រោះចំនួន ០៣នាក់(ស្រី ០២នាក់ កុមារី ០១នាក់)។
- បានទទួលពលករចំណាកស្រុក ដែលបញ្ជូនត្រឡប់មកពីប្រទេសថៃនិរទេសចំនួន **១.១៩៨**នាក់ (ប្រុស ៦៦៣នាក់ ស្រី ៤២៥នាក់ កុមារា ៥៤នាក់ កុមារី ៥៦នាក់)។

## ខ.៤. កិច្ចការពារកុមារពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ

❖ **ការផ្សព្វផ្សាយ**

| ល.រ | ខេត្ត | ទីតាំងផ្សព្វផ្សាយ | កន្លែង/លើក | អ្នកចូលរួម | ស្ត្រី |
|---|---|---|---|---|---|
| ១ | សៀមរាប | -ធ្វើយុទ្ធនាការផ្សព្វផ្សាយ ស្តីពីការបង្ការ និងទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារ នៅតាមសហគ្រាស គ្រឹះស្ថាន ផលិតឥដ្ឋ ក្បឿង និងកសិ-ឧស្សាហកម្ម។ | ០១លើក | ៣៥០នាក់ | ២១១នាក់ |
| ២ | កណ្តាល | -ធ្វើយុទ្ធនាការផ្សព្វផ្សាយ ស្តីពីការបង្ការ និងទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារ និងចង | ៧៥សហគ្រាស | ១.៦៦៩នាក់ | ៨១៦នាក់ |

| | | | | | |
|---|---|---|---|---|---|
| | | បងាផ្សព្វផ្សាយ នៅតាមសហគ្រាស គ្រឹះស្ថាន ក្នុងវិស័យផលិតឥដ្ឋ និងក្បឿង។ -ធ្វើកិច្ចសន្យាហាមឃាត់ ការប្រើប្រាស់ពលកម្មកុមារជាមួយម្ចាស់សហគ្រាស និងធ្វើកិច្ចសន្យាជាមួយអាណាព្យាបាល។ | ៧៥សហគ្រាស | ៦៩៤គ្រួសារ | |
| ៣ | បន្ទាយមានជ័យ | -ផ្សព្វផ្សាយ ស្តីពីការបង្ការ និងទប់ស្កាតការប្រើប្រាស់កម្លាំងពលកម្មកុមារ ក្នុងសិប្បកម្មឡឥដ្ឋ។ | ០២លើក | ៧០នាក់ | ៤០នាក់ |
| ៤ | ក្រចេះ | -ផ្សព្វផ្សាយ ស្តីពីច្បាប់ការប្រើប្រាស់ពលកម្មកុមារ និងការងារប្រើប្រាស់បុគ្គលិកជាស្ត្រី នៅក្រុមហ៊ុនភួរៀងក្រចេះអភិវឌ្ឍន៍កៅស៊ូ។ | ០១លើក | | |
| ៥ | ប៉ៃលិន | -ផ្សព្វផ្សាយនិងចងបងា ស្តីពីការទប់ស្កាត់ការប្រើប្រាស់កម្លាំងពលកម្មកុមារ ក្នុងទម្រង់ធ្ងន់ធ្ងរនៅតាមសហគ្រាស គ្រឹះស្ថាន។ | ១៨សហគ្រាស | ២០៦នាក់ | ៧៦នាក់ |

❖ **ការធ្វើអធិការកិច្ច**

| ល.រ | ខេត្ត | សកម្មភាព | កន្លែង/លើក | អ្នកចូលរួម | ស្ត្រី |
|---|---|---|---|---|---|
| ១ | កណ្តាល | -ចុះធ្វើអធិការកិច្ចការងារ ពិសេសត្រួតពិនិត្យលើសហគ្រាសផលិតឥដ្ឋ និងក្បឿង ស្ថិតនៅស្រុកមុខកំពូល។ ទទួលបណ្តឹងពីកម្មករពាក់ព័ន្ធពាន់នឹងការជំពាក់ប្រាក់ឈ្នួល ៥,២៥០,០០០រៀល តាំងពីខែកុម្ភៈ ឆ្នាំ២០២៤មក ក្រោយមន្ទីរសម្រេចដាក់កំហិត ដល់ម្ចាស់សហគ្រាសត្រូវបើកប្រាក់ជំពាក់គ្រប់ចំនួន នៅថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៥។ | ០១ទីតាំង | ៤៦នាក់ | ២៣នាក់ |

## ខ.៥. ការលើកកម្ពស់ជីវភាព

| ល.រ | សកម្មភាពថ្នាក់ក្រោមជាតិ | ចំនួន | អ្នកទទួលសេវា | ស្ត្រី |
|---|---|---|---|---|
| ១ | **ខេត្តកណ្តាល៖** មន្ទីរកិច្ចការនារីខេត្ត បានសហការជាមួយនាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ច នៃក្រសួងកិច្ចការនារី ក្រោមការឧបត្ថម្ភគាំទ្របច្ចេកទេស និងថវិកាពីអង្គការ (AAR Japan) រៀបចំវគ្គផ្សព្វផ្សាយស្តីពីការស្វែងរកការងារ និងមូលដ្ឋានគ្រឹះសម្រាប់អាជីវកម្ម។ | ០១លើក | ៣០នាក់ | ២៥នាក់ |
| ២ | **ខេត្តកំពង់ចាម៖** មន្ទីរកិច្ចការនារីខេត្ត<br>-បើកវគ្គបណ្តុះបណ្តាលកែច្នៃចំណីអាហារ ដើម្បីជួយដល់ស្ត្រីនៅសហគមន៍មានមុខរបរចិញ្ចឹមជីវិត។<br>-បើកវគ្គផ្សព្វផ្សាយ ស្តីពីបង្កើនការយល់ដឹង និងការគាំទ្រជាសាធារណៈ លើភាពជាអ្នកដឹកនាំរបស់ស្ត្រី និងក្មេងស្រីនៅគ្រប់កម្រិត។ | ០៣លើក<br>០២លើក | ១៤៤នាក់<br>៩៧នាក់ | ១៣៨នាក់<br>៣២នាក់ |
| **សរុប** | | **០៦លើក** | **២៧១នាក់** | **១៩៥នាក់** |

## គ. ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស

### គ.១. ការខារអនុវត្តច្បាប់

❖ **ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ**

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ព្រមទាំងកងរាជអាវុធហត្ថលើផ្ទៃប្រទេស បានតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ សរុបចំនួ **២០**ករណី (ប្រៀបធៀបខែមីនា មានចំនួន ១៨ករណី កើនឡើង ០២ករណី) ស្មើនឹង ១១,១១% ៖

- ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងរាជធានី-ខេត្ត ចំនួន **២១**នាក់ (ស្រី០៣នាក់) ជនជាតិចិន ចំនួន០១នាក់។
- សង្គ្រោះជនរងគ្រោះចំនួន **៤០**នាក់ មានអាយុក្រោម១៥ឆ្នាំ ២០នាក់ អាយុ១៥-១៧ឆ្នាំ ០៥នាក់ និងអាយុ១៨ឆ្នាំឡើង ១៥នាក់ (បញ្ជូនទៅមន្ទីរសង្គមកិច្ច ១៦នាក់ គ្រួសារ២៤នាក់)។ ក្នុងនោះចែកជា៖

**ករណីអំពើជួញដូរមនុស្ស**

បង្ក្រាបបាន **០៥/០៨ករណី** (ថយចុះ ០៣ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន **០៦**នាក់។ សង្គ្រោះជនរងគ្រោះ **១៤**នាក់ មានអាយុក្រោម១៥ឆ្នាំ ០១នាក់ អាយុ១៥-១៧ឆ្នាំ ០១នាក់ និងអាយុ១៨ឆ្នាំឡើង ១២នាក់ (បញ្ជូនទៅមន្ទីរសង្គមកិច្ច ០១នាក់ គ្រួសារ ១៣នាក់)។

*តារាងស្ថិតិបទល្មើសជួញដូរមនុស្ស*

| បទល្មើស | ករណី | ជនសង្ស័យ | ជនរងគ្រោះ |
|---|---|---|---|
| -ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន | ០១ | ០១ | គ្មាន |
| -អំពើលក់ដូរមនុស្ស | ០១ | ០២ | ០១ |
| -ការទទួលយកមនុស្សដោយមានគោលដៅជួយដល់ជនល្មើស | ០៣ | ០៣ | ១៣ |
| **សរុប** | **០៥ ករណី** | **០៦ នាក់** | **១៤ នាក់** |

**ករណីអំពើធ្វើអាជីវកម្មផ្លូវភេទ**

បង្ក្រាបបាន **១៥/១០ករណី** (កើនឡើង **០៥**ករណី) ឃាត់ខ្លួនជនសង្ស័យ **១៥**នាក់ (ស្រី**០៣**នាក់) ជនជាតិចិន ០១នាក់។ សង្គ្រោះជនរងគ្រោះ **២៦**នាក់ មានអាយុក្រោម១៥ឆ្នាំ ១៩នាក់ អាយុ១៥-១៧ឆ្នាំ ០៤នាក់ និងអាយុ១៨ឆ្នាំឡើង ០៣នាក់ (បញ្ជូនទៅមន្ទីរសង្គមកិច្ច ១៥នាក់ គ្រួសារ ១១នាក់)។

*តារាងស្ថិតិបទល្មើសអាជីវកម្មផ្លូវភេទ*

| បទល្មើស | ករណី | ជនសង្ស័យ | ជនបរទេស | ជនរងគ្រោះ |
|---|---|---|---|---|
| -សញ្ចារកម្ម | ០១ | ០១ | | ០១ |
| -សញ្ចារកម្មទាក់ទងនឹងពេស្យាចារកុមារ | ០២ | ០២ | | ០៩ |
| -អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | ១០ | ១០ | ចិន១ | ១០ |
| -អំពើអាសប្រឆាំងនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ | ០២ | ០២ | | ០៦ |
| **សរុប** | **១៥ ករណី** | **១៥ នាក់** | **០១ នាក់** | **២៦ នាក់** |

## ឃ. កិច្ចការពារជនរងគ្រោះ

### ឃ.១. ការទទួល និងសម្ភាសពលករបញ្ជូនទាំងក្នុងប្រទេស និងត្រឡប់ពីក្រៅប្រទេស

ក្រុមការងារការពារជនរងគ្រោះ នៃ គ.ជ.ប.ជ ដឹកនាំដោយ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សហការជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ អគ្គស្នងការដ្ឋាននគរបាលជាតិ

អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ អគ្គនាយកដ្ឋានអន្តោប្រវេសន៍ និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត និងអង្គការដៃគូ តាមរយៈនាយកដ្ឋានគាំពារជនរងគ្រោះ នៃអគ្គនាយកដ្ឋានសេវាសង្គមកិច្ច បានទទួលជនរងគ្រោះ និងបុគ្គលសង្ស័យថារងគ្រោះដោយអំពើជួញដូរមនុស្ស ក្នុងប្រទេស និងក្រៅប្រទេស សរុបចំនួន ២១នាក់(ប្រុស ០១នាក់ ស្រី១៩នាក់ កុមារី ០១នាក់)។ ជនរងគ្រោះក្រោយពីទទួលបានការកំណត់អត្តសញ្ញាណពីមន្ត្រីនគរបាលយុត្តិធម៌ជំនាញចំនួន ១៨នាក់ (ប្រុស ០១ នាក់ ស្រី ១៧នាក់) ក្នុងនោះមាន៖

- ជនរងគ្រោះ និងបុគ្គលសង្ស័យថារងគ្រោះ មកពីក្រៅប្រទេសចំនួន ២០នាក់(ប្រុស ០១នាក់ ស្រី ១៨នាក់ កុមារី ០១នាក់) ប្រទេសចិន ១៥នាក់ ជាករណីអាពាហ៍ពិពាហ៍ផ្ទុយពីធន្ទៈ និងប្រទេសថៃ ០៥នាក់ (ប្រុស ០១នាក់ ស្រី ០៣នាក់ កុមារី ០១នាក់) ករណីកេងប្រវ័ញ្ចកម្លាំងពលកម្ម ០២នាក់ (ប្រុស០១នាក់, ស្រី០១នាក់) និងបុគ្គលសង្ស័យថារងគ្រោះចំនួន ០៣នាក់ (ស្រី០២នាក់ កុមារី០១នាក់)។
- ជនរងគ្រោះក្នុងប្រទេស ជាជនជាតិខ្មែរចំនួន ០១នាក់(ស្រី)ករណីអាពាហ៍ពិពាហ៍ផ្ទុយពីធន្ទៈ។

**ឃ.២. ការស្តារនីតិសម្បទា**

ជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស បានបញ្ជូនទៅស្តារនីតិសម្បទា នៅមជ្ឈមណ្ឌលរបស់អង្គការដៃគូ សរុបចំនួន ២១នាក់ (ប្រុស ០១នាក់ ស្រី ២០នាក់)៖ ទទួលសេវាពីអង្គការកោរីតាសកម្ពុជា០១នាក់ អង្គការអាជហុក ០២នាក់ អង្គការរតនៈអន្តរជាតិ ១៣នាក់ ទៅសហគមន៍ ០៤នាក់(ប្រុស ០១នាក់ ស្រី ៣នាក់) និងស្នាក់នៅក្នុងមជ្ឈមណ្ឌលស្តារនីតិសម្បទា កុមារី ០១នាក់។

**ឃ.៣. ការធ្វើសមាហរណកម្មជនរងគ្រោះ និងបុគ្គលសង្ស័យថារងគ្រោះ**

បានសហការជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គការដៃគូ ធ្វើសមាហរណកម្មជនរងគ្រោះ និងបុគ្គលសង្ស័យថារងគ្រោះដោយអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទ ត្រឡប់ទៅសហគមន៍វិញសរុបចំនួន ៥០នាក់ (ប្រុស ០១នាក់ ស្រី ៤២នាក់ កុមារី ០៧នាក់)។

**ឃ.៤. ការតាមដានករណី**

បានតាមដានករណីជនរងគ្រោះ និងបុគ្គសង្ស័យថារងគ្រោះដោយអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្រោយពីធ្វើសមាហរណកម្មទៅសហគមន៍ ចំនួន ៩១នាក់ (ប្រុស ១០នាក់ ស្រី ៨១នាក់)។

**ឃ.៥. ការការបិទករណី**

បានបិទករណី នៃការផ្តល់សេវាដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ចំនួន ៣៣នាក់ (ស្រី ៣១នាក់ កុមារី ០២នាក់។

## III. ការលើកកម្ពស់សមត្ថភាព និងការដឹកនាំសម្របសម្រួល

### ក. ការបណ្តុះបណ្តាល និងសិក្ខាសាលា

#### ក.១. ការបណ្តុះបណ្តាល

❖ ការបណ្តុះបណ្តាលក្នុងប្រទេស

| ល.រ | សកម្មភាពរៀបចំវគ្គបណ្តុះបណ្តាល | ចំនួនវគ្គ | ចំនួនរួម | ចំនួនស្ត្រី |
|---|---|---|---|---|
| ១ | នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានសហការជាមួយអង្គការម៉ារីស៊ី បើកវគ្គបណ្តុះបណ្តាល ស្តីពីការប្រមូលព័ត៌មាន ភស្តុតាង ការកំណត់អត្តសញ្ញាណ និងការកសាងសំណុំរឿង ដល់មន្ត្រីជំនាញនាយកដ្ឋាន។ | ០១ | ៦០ | ១២ |

| | | | | |
|---|---|---|---|---|
| ២ | **ខេត្តបាត់ដំបង៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានរៀបចំវគ្គបណ្តុះបណ្តាល ស្តីពីការចែករំលែកចំណេះដឹងទេសន្តរប្រវេសន៍ ការងារដល់អាជ្ញាធរមូលដ្ឋាន មន្ទីរ អង្គភាពពាក់ព័ន្ធ និងទីភ្នាក់ងារជ្រើសរើសឯកជន។ | ០១ | ៣៦ | ២៦ |
| | សរុប | ០២លើក | ៩៦នាក់ | ៣៨នាក់ |

**ក.២. សិក្ខាសាលានៅក្រៅប្រទេស**

▪ **អគ្គលេខាធិការ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស** បានចាត់បញ្ជូន លោកជំទាវ ឧត្តមសេនីយ៍ទោ **រ៉ែន សិរីលក្ខិណា** អគ្គលេខាធិការរង និងជាក្រុមការងារ SOMTC-កម្ពុជា ទៅចូលរួមសិក្ខាសាលា ដើម្បីពិភាក្សាលើគោលការណ៍ណែនាំ កិច្ចសហប្រតិបត្តិការជាក់ស្តែង នៃការស៊ើបអង្កេតបទល្មើសជួញដូរមនុស្សឆ្លងដែន ក៏ដូចជាពិភាក្សាទៅលើ MOR របស់HSU រៀបចំដោយ UNODC និង SOMTC-ហ្វីលីពីន សមាសភាពចូលរួមក្នុងសិក្ខាសាលាមានបណ្តាប្រទេសដែលជាសមាជិក SOMTC ចំនួន ១០ប្រទេស សរុប **៤១**នាក់ (ស្រី **១៧**នាក់) នៅទីក្រុងកូឡាឡាំពួរ ប្រទេសម៉ាឡេស៊ី។

## ខ. សន្និសីទ កិច្ចប្រជុំ ទស្សនកិច្ច និងជំនួបពិភាក្សាការងារ

### ខ.១. កិច្ចប្រជុំ

❖ **ការរៀបចំកិច្ចប្រជុំក្នុងប្រទេស**

▪ **អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស** បានរៀបចំកិច្ចប្រជុំ ចំនួន **០៦**លើក អ្នកចូលរួមចំនួន **៥៦**នាក់ (ស្រី **១៣**នាក់)៖

- កិច្ចប្រជុំផ្ទៃក្នុង ពិនិត្យសេចក្តីព្រាងឧបករណ៍ប្រមូលទិន្នន័យ នៃកុមារដែលរងគ្រោះដោយការធ្វើទេសន្តរប្រវេសន៍ ចំនួន **០១**លើក អ្នកចូលរួមចំនួន **១៤**នាក់ (ស្រី **០៤**នាក់) នៅសាលប្រជុំ គ.ជ.ប.ជ។

- កិច្ចប្រជុំផ្ទៃក្នុង ត្រួតពិនិត្យ និងកែសម្រួលផែនការសកម្មភាព និងផែនការថវិកា សម្រាប់អនុវត្តឆ្នាំ២០២៥ របស់ការិយាល័យចំណុះលេខាធិការដ្ឋានរដ្ឋបាលសរុប ចំនួន **០១**លើក អ្នកចូលរួមចំនួន **០៦**នាក់ (ស្រី **០១**នាក់) នៅសាលប្រជុំ គ.ជ.ប.ជ។

- កិច្ចប្រជុំផ្ទៃក្នុង ស្តីពីការត្រៀមរៀបចំផែនការយុទ្ធសាស្ត្រថវិកា ៣ឆ្នាំរំកិល (២០២៦-២០២៨) និងគម្រោងផែនការថវិកា ប្រចាំឆ្នាំ២០២៦ របស់អង្គភាពថវិកាចំណុះក្រសួងមហាផ្ទៃ ចំនួន **០១**លើក អ្នកចូលរួមចំនួន **០៨**នាក់ (ស្រី **០២**នាក់) នៅសាលប្រជុំ គ.ជ.ប.ជ។

- កិច្ចប្រជុំផ្ទៃក្នុងស្តីពី (១).ការពិនិត្យលើឯកសារ ឬលិខិតបទដ្ឋានគតិយុត្តនានា (២).ការត្រៀមប្រមូលផែនការថវិកាតាមក្រុមនីមួយៗ ដើម្បីរៀបចំផែនការថវិការួម របស់ គ.ជ.ប.ជ និង(៣).ការត្រួតពិនិត្យរបាយការណ៍ និងឯកសារពាក់ព័ន្ធផ្សេងៗ ដើម្បីឆ្លើយតបនឹងមន្ត្រីសវនកម្ម ដែលនឹងចុះមកត្រួតនិត្យនៅក្នុងខែឧសភាខាងមុន ចំនួន **០១**លើក អ្នកចូលរួមចំនន **១៣**នាក់ (ស្រី **០១**នាក់) នៅសាលប្រជុំ គ.ជ.ប.ជ។

- កិច្ចប្រជុំផ្ទៃក្នុង ស្តីពីការត្រួតពិនិត្យលើផែនការសកម្មភាពឆ្នាំ២០២៥ របស់ក្រុមជំនួយកិច្ចការទាំង ០៦ ចំនួន **០១**លើក អ្នកចូលរួមចំនួន **០៨**នាក់ (ស្រី **០១**នាក់) នៅសាលប្រជុំ គ.ជ.ប.ជ។

- កិច្ចប្រជុំត្រៀមសម្រាប់កិច្ចសន្ទនាទ្វេភាគី «The Regional Dialogue and Knowledge Exchange between Cambodia and Philippines» ដែលនឹងប្រព្រឹត្តទៅនៅទីក្រុងម៉ានីឡា ប្រទេសហ្វីលីពីន ជាមួយ ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាសមាសភាពគណៈប្រតិភូ គ.ជ.ប.ជ អន្តរក្រសួង ស្ថាប័ន ចំនួន **០១**លើក អ្នកចូលរួមចំនួន **០៧**នាក់ (ស្រី **០៤**នាក់) នៅបន្ទប់ប្រជុំទីស្តីការក្រសួងមហាផ្ទៃ។

▪ **ខេត្តព្រះវិហារៈ គណៈកម្មាធិការ គ.ខ.ប.ជ** បានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងកិច្ចសហប្រតិបត្តិជាមួយប្រទេសថៃ-ឡាវ ប្រចាំត្រីមាស១ ឆ្នាំ២០២៥ ក្រោមអធិបតីភាព ឯកឧត្តម **គីម រិទ្ធី** អភិបាល នៃគណៈអភិបាលខេត្តព្រះវិហារ នៅសាលប្រជុំប្រាសាទព្រះវិហារ អគាររដ្ឋបាលសាលាខេត្ត ចំនួន **០១**លើក អ្នកចូលរួមចំនួន **១៧**នាក់ (ស្រី **១០**នាក់)។

❖ **ការចូលរួមកិច្ចប្រជុំក្នុងប្រទេស និងនៅក្រៅប្រទេស**

▪ **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស** លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានដឹកនាំគណៈប្រតិភូ នៃគណៈកម្មាធិការជាតិ គ.ជ.ប.ជ ដែលមានតំណាងមកពី ស្ថានទូតកម្ពុជាប្រចាំនៅហ្វីលីពីន ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងយុត្តិធម៌ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ អគ្គស្នងការដ្ឋាននគរបាលជាតិ និងអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ទៅចូលរួមកិច្ចសន្ទនាថ្នាក់តំបន់ និងការផ្លាស់ប្តូរចំណេះដឹងរវាងកម្ពុជា និងហ្វីលីពីន The Regional Dialogue and Knowledge Exchange Between Cambodia and the Philippines " នៅទីក្រុងម៉ានីល ប្រទេសហ្វីលីពីន។

## គ. ការខារសម្របសម្រួល

ការងាររៀបចំដឹកនាំសម្របសម្រួលកិច្ចប្រជុំ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅទូទាំងប្រទេស គឺ **៣៣**លើក មានអ្នកចូលរួមសរុប **៧៧៥**នាក់(ស្រី **២៦១**នាក់) ក្នុងនោះមាន គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ចំនួន **១៧**លើក និងលេខាធិការដ្ឋានរាជធានី-ខេត្ត ចំនួន **១៦**លើក។ (ឧបសម្ព័ន្ធ)

# IV. ការសន្និដ្ឋានវាយតម្លៃ

## ក.ចំណុចខ្លាំង

តាមរយៈការខិតខំប្រឹងប្រែងរបស់ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) សម្រេចការងារជាលទ្ធផលជោគជ័យគួរឱ្យកត់សម្គាល់៖

- ការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល ក្នុងការកំណត់យកការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សជាអាទិភាពមួយ ក្នុងចំណោមអាទិភាពនៃផែនការដែលត្រូវយកចិត្តទុកដាក់ គឺជាថាមពលជំរុញចិត្តឱ្យគ្រប់សមាសភាពក្នុងសង្គមទាំងនៅថ្នាក់ជាតិ ទាំងនៅថ្នាក់ក្រោមជាតិ និងដៃគូ ជាតិ និងអន្តរជាតិ ឱ្យរឹតតែប្រឹងប្រែងទ្វេឡើងទៀត
- ច្បាប់ គោលនយោបាយ វិធានការ អនុសាសន៍របស់ប្រមុខដឹកនាំទាំងក្នុងនីតិកាលចាស់ និងថ្មី នៅតែមានគុណតម្លៃសម្រាប់ការអនុវត្ត ជាមូលដ្ឋានបង្អែក និងជាប្រទីបបំភ្លឺផ្លូវសម្រាប់ការកំណត់ការងារជាយុទ្ធសាស្ត្រប្រឆាំងអំពើជួញដូរមនុស្ស
- សន្ធិសញ្ញា កតិកាសញ្ញា អនុសញ្ញា អនុស្សរណៈនៃការយោគយល់ កិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី និងលិខិតបទដ្ឋានគតិយុត្តជាច្រើនផ្សេងទៀត នៅតែមានតម្លៃជាកិច្ចសហប្រតិបត្តិការទូលំទូលាយលើ វិស័យប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សគ្រប់ទម្រង់ និងអំពើពាក់ព័ន្ធដទៃទៀត
- រចនាសម្ព័ន្ធនៃយន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ជាកម្លាំងស្នូលក្នុងការអនុវត្តការងារ តាមក្រសួង ស្ថាប័ន មន្ទីរ អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល វិស័យឯកជន បានចូលរួមយ៉ាងសកម្មក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើពាក់ព័ន្ធទាំងឡាយក្នុងសង្គមកម្ពុជា
- ការចូលរួមឧបត្ថម្ភគាំទ្រពីអង្គការសង្គមស៊ីវិលជាតិ អន្តរជាតិ វិស័យឯកជន និងកិច្ចសហការក្នុងការបំពេញភារកិច្ចតាមក្រសួង ស្ថាប័ន មន្ទីរ អង្គភាព គឺជាកម្លាំងសរុប ធនធានសរុប និងមធ្យោបាយសរុបសម្រាប់រួមគ្នាធ្វើសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សដ៏មានសក្តានុពល។

## ខ. ចំណុចខ្វះខាត ឬភាពប្រឈម

ទន្ទឹមនឹងការខិតខំប្រឹងប្រែង យើងពិនិត្យឃើញនៅមានចំណុចប្រឈម មួយចំនួនដូចជា៖

- ទាមទារការយកចិត្តទុកដាក់បន្ថែមទៀត លើការចាត់តាំងមន្ត្រីទទួលបន្ទុកឱ្យបានជាក់លាក់ លើការងាររបាយការណ៍ ការងារផែនការ ការងារសេម្របសម្របសម្រួល ការងាររដ្ឋបាលហិរញ្ញវត្ថុ សម្រាប់អនុវត្តយុទ្ធសាស្ត្រប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅតាមក្រសួងស្ថាប័ន មន្ទីរអង្គភាពនីមួយៗ ចៀសវាងការផ្លាស់ប្តូរញឹកញាប់ ឬគ្មានអ្នកទទួលខុសត្រូវច្បាស់លាស់ នាំឱ្យធកល្វែង ។
- ត្រូវការពិភាក្សាបន្ថែម លើការកំណត់ឯកតាសម្រាប់ទិន្នន័យនៃរបាយការណ៍ ឧទាហរណ៍ ពាក្យថា ជនរងគ្រោះ ជនងាយរងគ្រោះ ជនសង្ស័យថារងគ្រោះ... ដែលធ្វើឱ្យការបូកសរុប ទាំងបរិមាណ និងគុណភាព មិនទាន់ស៊ីចង្វាក់គ្នា
- ជនល្មើសមានកលល្បិចជ្រៀតចូលធ្វើសកម្មភាពខុសច្បាប់ និងអូសទាញមនុស្សឱ្យរងគ្រោះជាបន្តបន្ទាប់
- ខ្វះវិធីសាស្ត្រ និងសង្គតិភាពនៃសារអប់រំ ដែលមានប្រសិទ្ធភាព និងអាចបង្ការទប់ស្កាត់បាននូវអំពើជួញដូរ និងកេងប្រវ័ញ្ចគ្រប់ទម្រង់។

## គ. សេចក្តីសន្និដ្ឋាន និងសំណូមពរ

បទល្មើសជួញដូរមនុស្ស និងបទល្មើសដទៃទៀត មានភាពប្រទាក់ក្រឡាគ្នា កាន់តែស្មុគស្មាញ និងរីកសាយធាប់រហ័ស អាស្រ័យដោយការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាទំនើបជាមធ្យោបាយសម្រាប់បង្កើនប្រសិទ្ធភាពបទល្មើសឱ្យកាន់តែមានកម្រិតខ្ពស់ និងអាចខ្ពស់ជាងបច្ចេកទេសដែលសមត្ថកិច្ចប្រើប្រាស់បច្ចុប្បន្ន។ ករណីខ្លះ ជនល្មើស និងជនរងគ្រោះ ជាមនុស្សតែមួយ និងមានបណ្តាញប្រទាក់ក្រឡាពីកន្លែងមួយ ទៅកន្លែងមួយ ពីប្រទេសមួយ ទៅប្រទេសមួយ។ ករណីភាគច្រើន មិនពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សទេ តែបង្កប់នូវបទល្មើសផ្សេងទៀត មានជាអាទិ៍ អំពើឆបោក អំពើចាប់ជំរិត គំនុំ ទំនាស់ការងារ ប្រព្រឹត្តខុសច្បាប់ការងារ ខុសច្បាប់អន្តោប្រវេសន៍ ការបន្លំជាជនរងគ្រោះដើម្បីគេចពីសំណាញ់ច្បាប់ ជាដើម។

យុទ្ធសាស្ត្របង្ការទប់ស្កាត់ នៅតែជាអាទិភាព ដែលអាចការពារមិនឱ្យមនុស្សគ្រប់វ័យពីដំណាក់កាលដំបូង ដោយមិនរង់ចាំឱ្យដល់ដំណាក់កាលរងគ្រោះ ព្រោះវានឹងធ្វើឱ្យខូចខាត ទាំងធនធានមនុស្ស ធនធានថវិកា ពេលវេលា ទំនាក់ទំនងសង្គម និងការអភិវឌ្ឍន៍គ្រប់វិស័យ។

ការពង្រឹងស្ថាប័ន សមត្ថភាពជំនាញ និងឥរិយាបថមន្ត្រីគ្រប់ឋានានុក្រម និងការពិនិត្យឡើងវិញ នូវនីតិវិធីច្បាប់ ក៏ដូចជាកិច្ចសហការរវាងវិស័យពាក់ព័ន្ធ ប្រទេសពាក់ព័ន្ធ ក្នុងតំបន់ និងជាអន្តរជាតិ នៅតែមានភាពចាំបាច់មិនអាចខ្វះបាន ក្នុងការកាត់បន្ថយ ឈានទៅលុបបំបាត់រាល់ទម្រង់នៃអំពើជួញដូរមនុស្ស និងអំពើពាក់ព័ន្ធ។

ជាសំណូមពរ ចំពោះ ក្រសួង ស្ថាប័ន មន្ទីរ អង្គភាព ក្នុងយន្តការនៃគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស៖

- គប្បីរៀបចំចាត់តាំងមន្ត្រីទទួលខុសត្រូវ បំពេញតាមរចនាសម្ព័ន្ធគណៈកម្មាធិការគ្រប់ថ្នាក់ឱ្យបានច្បាស់លាស់ ប្រកបដោយការទទួលខុសត្រូវ រួមទាំងមន្ត្រីលេខាធិការដ្ឋាន ទទួលបន្ទុក ការងាររបាយការណ៍ ផែនការ និងការងាររដ្ឋបាល ហិរញ្ញវត្ថុ ដើម្បីងាយស្រួលដល់ការរៀបចំវគ្គបណ្តុះបណ្តាលតាមជំនាញសម្រាប់ការអនុវត្តការងារឲ្យទទួលបានប្រសិទ្ធភាពខ្ពស់
- ពង្រឹងកិច្ចប្រជុំក្រុមការងារអន្តរក្រសួង ស្ថាប័ន នៅថ្នាក់ជាតិ និងកិច្ចប្រជុំគណៈកម្មាធិការ និងលេខាធិការដ្ឋានខេត្ត ក្រុង ស្រុក ខណ្ឌ (គ.ខ/រ.ប.ជ) ឱ្យបានទៀងទាត់ប្រចាំខែ ឬត្រីមាស ដើម្បីបូកសរុបរបាយការណ៍ វាយតម្លៃលើសកម្មភាព និងលទ្ធផលនៃការអនុវត្តផែនការតាមយុទ្ធសាស្ត្រនីមួយៗ។

## V. ទិសដៅខែឧសភា ឆ្នាំ ២០២៥

ដើម្បីកែលម្អចំណុចខ្វះខាត និងពង្រឹងប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រទាំងបួន ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរបៀបរបបការងារឱ្យកាន់តែល្អប្រសើរ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដាក់ចេញនូវទិសដៅដូចខាងក្រោម៖

១. បន្តពង្រឹងកិច្ចសហការទូលំទូលាយតាមរយៈ ការជួបប្រជុំពិភាក្សា បង្កើតសកម្មភាពផ្តែកលើយុទ្ធសាស្ត្ររួម ដែលបានកំណត់ និងចូលរួមបែងចែកភារកិច្ច ពង្រាយកម្លាំង និងការទទួលខុសត្រូវ ឆ្ពោះទៅកាន់គោលដៅរួម គឺការបង្ការ ទប់ស្កាត់ ឈានទៅលុបបំបាត់អំពើជួញដូរមនុស្សគ្រប់ទម្រង់

២. ត្រៀមកិច្ចប្រជុំពិគ្រោះយោបល់រវាងក្រុមប្រទេសបញ្ជូន និងប្រទេសទទួល ដើម្បីពង្រឹងកិច្ចសហការចែករំលែកការទទួលខុសត្រូវ និងការពារផលប្រយោជន៍ពលករ ជាពិសេសពលករក្នុងឧស្សាហកម្មនេសាទ ព្រមទាំងនិយោជក រវាងប្រទេសបញ្ជូន និងប្រទេសទទួលប្រកបដោយសមធម៌

៣. គាំទ្រ ពង្រឹងសមត្ថភាពជំនាញពាក់ព័ន្ធគ្រប់ផ្នែក ដល់មន្ត្រីជំនាញ ពង្រឹងការគ្រប់គ្រង របៀបរបបការងាររបស់ក្រុមការងារ និងលេខាធិការដ្ឋានរាជធានី-ខេត្ត

៤. បន្តការងារផ្សព្វផ្សាយអប់រំតាមគ្រប់រូបភាព និងប្រើគ្រប់លទ្ធភាព និងធនធាន ដើម្បីលើកកម្ពស់ការយល់ដឹងជាសកល អំពីការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ទំនាក់ទំនងរវាងទេសន្តរប្រវេសន៍ និងអំពើជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀត ឱ្យបានដល់ប្រជាពលរដ្ឋជាពិសេសស្រទាប់យុវវ័យ ក្នុងសាលារៀន និងក្រៅសាលារៀន និងជនដែលងាយរងគ្រោះ

៥. បន្តរៀបចំសកម្មភាពបណ្តុះបណ្តាលមន្ត្រី ពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះ នៅតាមបណ្តាក្រសួង ស្ថាប័ន អង្គការដៃគូក្នុងស្រុក និងមន្ត្រីប្រចាំស្ថានទូតកម្ពុជាក្នុងប្រទេសគោលដៅ ព្រមទាំងចុះតាមដាន ការអនុវត្ត

៦. ជំរុញតាមដានត្រួតពិនិត្យក្រុមហ៊ុនបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេស ឱ្យអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលឱ្យបានត្រឹមត្រូវ

៧. ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេសការពង្រឹងកិច្ចសហការក្នុងការជួយគ្នាទៅវិញទៅមក ក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ ជាមួយប្រទេសពាក់ព័ន្ធ

៨. បន្តអនុវត្ត និងចូលរួមយ៉ាងសកម្ម ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព របស់រាជរដ្ឋាភិបាល

៩. ជំរុញសាងសង់ជម្រកបណ្តោះអាសន្ន នៅតាមច្រកព្រំដែនសំខាន់ៗ ដែលមានការបញ្ជូនត្រឡប់ពីប្រទេសថៃ នៅតែមានជាប់បន្ត ជារៀងរាល់ថ្ងៃ ដោយមានមន្ត្រីប្រចាំការ សម្រាប់ការផ្តល់សេវាចាំបាច់មួយចំនួន ដូចជាការពិនិត្យ ព្យាបាលសុខភាពបឋម អាហារ សម្រាប់មនុស្សចាស់ កុមារ ទារក ការស្នាក់នៅបណ្តោះអាសន្នមុនពេលចេញដំណើរ ការសាកសួរសុខទុក្ខ សម្របសម្រួល និងស្តាប់សំណូមពរដើម្បីបន្តដោះស្រាយនៅនឹងកន្លែង ឬនៅតាមបណ្តាខេត្តប្រភពរបស់ពលករជាដើម។

ថ្ងៃ.....៧កើត.....ខែ.....ជេស្ឋ..... ឆ្នាំ ម្សាញ់ សប្តស័ក ព.ស ២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី....៥.... ខែ....មិថុនា.... ឆ្នាំ២០២៥

**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

ជួ_ប៊ុនអេង

**ចម្លងជូន**

-ខុទ្ទកាល័យ សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យ ឯកឧត្តមអភិសន្តិបណ្ឌិត ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ

"ដើម្បីគោរពជូនជាសេចក្តីរាយការណ៍"

-ឯកឧត្តម លោកជំទាវ ប្រធានក្រុមការងារជំនាញ អន្តរក្រសួង ស្ថាប័ន

-សមាជិកក្រុមការងារគ.ជ.ប.ជ

-អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

"ដើម្បីជូនជ្រាប"

-ឯកសារ កាលប្បវត្តិ

## ឧបសម្ព័ន្ធ

## តារាងការងារដឹកនាំ និងសម្របសម្រួល កិច្ចសហប្រតិបត្តិការ (សរុបចំនួន ៣៣លើក) មនុស្សចំនួន ៧៧៥នាក់ (ស្រី ២៦១នាក់)

| ស្ថាប័នសម្របសម្រួល | សកម្មភាព |
|---|---|
| គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) | ▪ លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញចូលរួម<br>-កិច្ចប្រជុំប្រចាំឆ្នាំ២០២៤ និងទិសដៅបន្តឆ្នាំ២០២៥ របស់គណៈកម្មាធិការជាតិលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ ក្នុងនាមជាអនុប្រធានគណៈកម្មាធិការជាតិ នៅសណ្ឋាគារសាន់&មូន រីវើសាយ រាជធានីភ្នំពេញ។<br>-ដឹកនាំក្រុមការងារអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ចុះពិនិត្យស្ថានភាពពលករឆ្លងកាត់ព្រំដែន ចុះសួរសុខទុក្ខ សំណេះសំណាល និងនាំយកនូវសម្ភារៈប្រើប្រាស់ ថ្នាំពេទ្យ និងអាហារសម្រន់ ជូនបងប្អូនប្រជាពលរដ្ឋកម្ពុជា ដែលកំពុងវិលត្រឡប់មកមាតុប្រទេសវិញ ក្នុងឱកាសចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ នៅច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត កំរៀង ភ្នំដី និងអូរស្មាច់។<br>-ជាអធិបតីក្នុងកិច្ចប្រជុំតម្រង់ទិសគម្រោងសុវត្ថិភាពទេសន្តរប្រវេសន៍កម្ពុជា ជំហានទី២ ដែលរៀបចំដោយអង្គការការីតាសស្វីស នៅខេត្តបាត់ដំបង។<br>-កិច្ចប្រជុំត្រៀមសម្រាប់ កិច្ចសន្ទនាទ្វេភាគី "The Regional Dialogue and Knowledge Exchange between Cambodia and Philippines" ដែលនឹងប្រព្រឹត្តទៅនៅទីក្រុងម៉ានីឡា ប្រទេសហ្វីលីពីន ជាមួយលោកជំទាវ ឯកអគ្គរដ្ឋទូតនៃសាធារដ្ឋហ្វីលីពីន តាមប្រព័ន្ធ Zoom។<br>-ដឹកនាំក្រុមការងារអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ចុះបំពេញបេសកកម្មដើម្បីពិនិត្យ និងតាមដានការអនុវត្តការងារ របស់លេខាធិការដ្ឋាន នៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តព្រះសីហនុ។<br>▪ លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជ. **ប៉ុណ្ណ សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ បានអញ្ជើញចូលរួម<br>-ពិធីសម្ពោធដាក់ឱ្យដំណើរការជាផ្លូវការទីស្នាក់ការផ្តល់សេវាអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ និងលិខិតឆ្លងដែន នៅអគារផ្សារទំនើប អ៊ីអនម៉ុលមានជ័យ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមអភិសន្តិបណ្ឌិត **ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងលោកជំទាវ។<br>-កិច្ចប្រជុំឆ្លងសេចក្តីព្រាងអនុក្រឹត្យ ស្តីពីការដាក់មន្ត្រីនគរបាលជាតិកម្ពុជា ឱ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស និងអនុក្រឹត្យស្តីពីឯកសណ្ឋាន និងសញ្ញាសម្គាល់នគរបាលជាតិកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមអភិសន្តិបណ្ឌិត **ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅទីស្តីការក្រសួងមហាផ្ទៃ។<br>-ក្នុងវេទិកាគោលនយោបាយ កាតាលីករសកលអាស៊ី-ប៉ាស៊ីហ្វិក សហការរៀបចំដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងអង្គការអន្តរជាតិខាងការងារ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅសណ្ឋាគារ ហៃយ៉ាត់ រីជិនស៊ី រាជធានីភ្នំពេញ។<br>▪ **លេខាធិការដ្ឋាន នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ**<br>-លិខិតរបស់ គ.ជ.ប.ជ៖ លិខិតចេញ (១៣ច្បាប់) លិខិតចូល (៣៤ច្បាប់) |

-លិខិតរបស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖ លិខិតចេញ(០៩ច្បាប់)លិខិតចូល(០៨ច្បាប់)

- **ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់**

-ប្រជុំក្នុងក្រុម ដើម្បីពិនិត្យ និងកែសម្រួលផែនការសកម្មភាព សម្រាប់អនុវត្តឆ្នាំ២០២៥ របស់ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់។

-ចូលរួមសិក្ខាសាលា ស្តីពីបរិវត្តកម្ម ប្រព័ន្ធបច្ចេកវិទ្យាឌីជីថលក្រសួងមហាផ្ទៃ នៅសាលប្រជុំ ទីស្តីការក្រសួងមហាផ្ទៃ។

-ចូលរួមកិច្ចប្រជុំការឆ្លុះបញ្ចាំង ស្តីពីការអនុវត្តគម្រោងសុវត្ថិភាពកុមារ តាមប្រព័ន្ធអនឡាញ ក្រោមអធិបតីភាព ឯកឧត្តម **គីម សុវណ្ណឌី** អគ្គលេខាធិការក្រុមប្រឹក្សាជាតិដើម្បីកុមារ នៅសណ្ឋាគារសាន់វេ រាជធានីភ្នំពេញ។

- **ក្រុមជំនួយកិច្ចការការពារជនរងគ្រោះ**

-ចូលរួមកិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារលើកទី១ អាណត្តិទី៧ នៃរាជរដ្ឋាភិបាលជាតិកម្ពុជា ក្រោមអធិបតីភាព ឯកឧត្តម **ជា សុមេធី** រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នៅសាលប្រជុំ ទីស្តីការក្រសួងសង្គមកិច្ច។

-ចូលរួមកិច្ចប្រជុំក្រុមការងារបច្ចេកទេស ដើម្បីសិក្សា និងរៀបចំអនុស្សរណៈនៃការយោយល់ ស្តីពីការពង្រឹង និងកិច្ចសហប្រតិការកិច្ចការពារកុមារ ដែលរងផលប៉ះពាល់ដោយទេសន្តប្រវេសន៍ រវាងប្រទេសថៃ និងប្រទេសកម្ពុជា ក្រោមអធិបតីភាព លោកជំទាវ **ញ៉េប សុភាព** រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នៅសាលប្រជុំ ទីស្តីការក្រសួងសង្គមកិច្ច។

-ចូលរួមសិក្ខាសាលាពិគ្រោះយោបល់ លើសេចក្តីព្រាង គោលនយោបាយជាតិ ស្តីពីទេសន្តប្រវេសន៍ការងារ ក្រោមអធិបតីភាព លោកជំទាវ **សុវណ្ណ វណ្ណារតន៍** រដ្ឋលេខាធិការ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅសណ្ឋាគារ ហ៊ីម៉ាវ៉ារី រាជធានីភ្នំពេញ។

- **ក្រុមជំនួយកិច្ចការទេសន្តប្រវេសន៍**

-ចូលរួមកម្មវិធីបើកយុទ្ធនាការផ្សព្វផ្សាយ ស្តីពីការបង្ការ និងទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារនៅតាមសហគ្រាស គ្រឹះស្ថាន ផលិតឥដ្ឋ ក្បឿង និងកសិ-ឧស្សាហកម្ម ឆ្នាំ២០២៥ នៅខេត្តសៀមរាប។

-ចូលរួមកិច្ចប្រជុំ គណៈកម្មការប្រឹក្សាគម្រោង ស្តីពីការពិនិត្យ និងការរៀបចំផែនការសកម្មភាពបន្តសម្រាប់អនុវត្តគម្រោង ILO-TRAINGLEឆ្នាំ២០២៥ នៅសណ្ឋាគារ កាំបូឌីយ៉ាណា រាជធានីភ្នំពេញ។

- **ក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ**

-ចូលរួមកិច្ចប្រជុំពង្រឹងរបៀបរបបការងារ បូកសរុបលទ្ធផលត្រីមាសទី៤ ឆ្នាំ២០២៤ និងត្រីមាសទី១ ឆ្នាំ២០២៥ របស់ក្រុមការងារទី២ នៃគណៈកម្មការចំពោះកិច្ចទី២ និងសម្រួលដំណើរចេញ-ចូល របស់ភ្ញៀវជាតិអន្តរជាតិ ជាពិសេសពលករ ក្រោមអធិបតីភាព ឯកឧត្តម **សៀក សុជាតិ** រដ្ឋលេខាធិការ ក្រសួងការពារជាតិ និងជាប្រធានក្រុមការងារទី២ នៃគណៈកម្មការចំពោះកិច្ចត្រួតពិនិត្យ និងដោះស្រាយបញ្ហាដំណើរចេញ-ចូល របស់ពលករខ្មែរតាមព្រំដែនកម្ពុជា នៅខេត្តបន្ទាយមានជ័យ។

| លេខាធិការដ្ឋាន គ.ខ.ប.ជ សម្របសម្រួលចំនួន ១៦លើក អ្នកចូលរួមសរុបចំនួន ៧៧៥នាក់ (ស្រី ២៦១នាក់) | |
|---|---|
| ខេត្តសៀមរាប | -គណៈកម្មាធិការ គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំប្រចាំខែមេសា ដើម្បីធ្វើការតាមដាន និងត្រួតពិនិត្យការអនុវត្តសកម្មភាពការងារ ចំនួន០១លើក អ្នកចូលរួមចំនួន ៧១នាក់ ស្រី៤២នាក់។<br>-លេខាធិការដ្ឋាន គ.ខ.ប.ជ បានប្រជុំពិភាក្សាលើផែនការសកម្មភាពសម្រាប់អនុវត្តត្រីមាសទី២ ចំនួន០១លើក អ្នកចូលរួមចំនួន០៥នាក់ ស្រី០៤នាក់។<br>-ក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅថ្នាក់ស្រុក បានរៀបចំកិច្ចប្រជុំ ចំនួន១០លើក អ្នកចូលរួមចំនួន២៨២នាក់ ស្រី១៣១នាក់។ |
| ខេត្តកណ្ដាល | -លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំប្រចាំខែមេសា ចំនួន០១លើក អ្នកចូលរួមចំនួន២៩៦នាក់ ស្រី០៩នាក់។<br>-ក្រុមការងារស្រុក បានរៀបចំកិច្ចប្រជុំប្រចាំខែមេសា ចំនួន០១លើក អ្នកចូលរួមចំនួន៧៩នាក់ ស្រី៥១នាក់។ |
| ខេត្តឧត្តរមានជ័យ | -លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំប្រចាំមេសា ចំនួន០១លើក អ្នកចូលរួមចំននួន២៣នាក់ ស្រី ១៣នាក់។ |
| ខេត្តព្រះវិហារ | -លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំត្រីមាស១ ចំនួន០១លើក អ្នកចូលរួមចំនួន១៩នាក់ ស្រី១១នាក់។ |